ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២

# សេចក្តីថ្លែងការណ៍រួមស្តីពីការបាត់បង់សត្វផ្សោតទន្លេមេគង្គពេញវ័យមួយក្បាល

*គេចាំបាច់ត្រូវដាក់ចេញនូវវិធានការអភិរក្សថ្មីៗដើម្បីជួយសង្គ្រោះសត្វផ្សោតទន្លេមេគង្គ ខណៈដែលការបន្តស្លាប់របស់សត្វផ្សោតបង្កឱ្យមានការព្រួយបារម្ភខ្លាំង*

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ WWF មានការសោកស្តាយជាពន់ពេកចំពោះការបាត់បង់នៃសត្វផ្សោតទន្លេមេគង្គឈ្មោលពេញវ័យមួយក្បាល មានទម្ងន់ ៩៣ គីឡូក្រាម មានប្រវែង ២១៥ ស.ម. ដែលត្រូវបានគេប្រទះស្លាប់អណ្តែតនៅចម្ងាយប្រមាណ ៣៦ គីឡូម៉ែត្រ ពីប៉ែកខាងក្រោមនៃអន្លង់សត្វផ្សោតកាំពី ក្នុងខេត្តក្រចេះ។ ក្រោយការពិនិត្យសាកសពរបស់សត្វផ្សោតកាលពីថ្ងៃទី១៣ ខែឧសភា អ្នកជំនាញវិទ្យាសាស្ត្រនៃក្រុមអ្នកស្រាវជ្រាវសត្វផ្សោតនៃរដ្ឋបាលជលផល និងអង្គការ WWF បានពិពណ៌នាឲ្យដឹងថា សត្វផ្សោតដែលបានស្លាប់មួយក្បាលនេះមានស្នាមរបួសនៅលើកន្ទុយរបស់វា និងមានស្នាមឆូតវែងមួយនៅផ្នែកខាងក្រោមនៃពោះខ្លួនរបស់វា។ ក្រុមអ្នកស្រាវជ្រាវបានប៉ាន់ប្រមាណថា សត្វផ្សោតនេះបានស្លាប់រយៈពេលពីរថ្ងៃហើយ ប៉ុន្តែក្រុមអ្នកវិទ្យាសាស្ត្រនៅមិនទាន់អាចសន្និដ្ឋានបានថា តើការស្លាប់នេះអាចបណ្តាលមកពីការជាប់នឹងមងនេសាទ ឬយ៉ាងណានោះនៅឡើយទេ ដោយហេតុថាលទ្ធផលនៃការធ្វើកោសល្យវិច្ច័យដំបូងមិនបានបញ្ជាក់ពីស្លាកស្នាមមងនេសាទនៅលើដងខ្លួននៃសាកសពរបស់សត្វផ្សោតនេះនោះទេ។

ខណៈចំនួនសរុបរបស់សត្វផ្សោតទន្លេមេគង្គកំពុងនៅសេសសល់តិចតួច ការស្លាប់របស់សត្វផ្សោតពេញវ័យដែលមានសុខភាពល្អមួយក្បាលនេះគឺជាពិតជាការសោកស្តាយមួយយ៉ាងខ្លាំង ព្រោះវាជាកត្តាមួយប៉ះពាល់ដោយផ្ទាល់ដល់លទ្ធភាពនៃបន្តពូជរបស់ហ្វូងសត្វផ្សោតទន្លេមេគង្គ។ បច្ចុប្បន្នសាកសពសត្វផ្សោតនេះត្រូវបានបញ្ជូនទៅរក្សាទុកនៅការិយាល័យរបស់អង្គការ WWF ក្នុងខេត្តក្រចេះ ដើម្បីឲ្យក្រុមអ្នកស្រាវជ្រាវបន្តការពិនិត្យបន្ថែមទៀតក្នុងគោលបំណងកំណត់ពីមូលហេតុពិតប្រាកដនៃការស្លាប់។

នេះជាសត្វផ្សោតពេញវ័យទី ៣ ហើយដែលបានស្លាប់ក្នុងរយៈពេល ៥ ខែដំបូងក្នុងឆ្នាំ២០២២នេះ ដែលក្នុងឆ្នាំដដែលនេះក្រុមអ្នកស្រាវជ្រាវក៏បានកត់ត្រាទុកការស្លាប់របស់កូនសត្វផ្សោតចំនួនពីរក្បាលផងដែរ។ ថ្វីបើរដ្ឋាភិបាលកម្ពុជាបានដាក់ចេញរួចហើយនូវការហាមឃាត់នៃការប្រើប្រាស់មងនេសាទនៅក្នុងដែនជម្រករបស់សត្វផ្សោតទន្លេ និងខណៈដែលអាជ្ញាធរមានសមត្ថកិច្ចនៃខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តបានបន្តពង្រឹងការអនុវត្តច្បាប់នៃការហាមឃាត់នេះហើយក៏ដោយ ចំនួនសត្វផ្សោតពេញវ័យភាគច្រើននៅតែបន្តស្លាប់ដោយសារការជាប់ទៅនឹងមងនេសាទដដែល។ នេះហើយជាហេតុផលសំខាន់មួយដែលថ្នាក់ដឹកនាំរដ្ឋបាលជលផលជាតិ និងខេត្ត ព្រមទាំងបុគ្គលិករបស់

អង្គការ WWF បានសហការចុះត្រួតពិនិត្យការងារកាលពីដើមសប្តាហ៍នេះ ក្នុងគោលបំណងពិនិត្យមើលសារឡើងវិញលើយុទ្ធសាស្ត្រ និងវិធានការនៃការពង្រឹងការអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋាននៃទីតាំងភូមិសាស្ត្រជម្រកសត្វផ្សោតតាមរយៈការរៀបចំឡើងនូវកិច្ចប្រជុំជាបន្តបន្ទាប់ជាមួយមន្ត្រីជលផលប្រចាំខេត្ត និងមន្ត្រីផ្ទាំទន្លេទាំងអស់ក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។ ជាលទ្ធផល កិច្ចប្រជុំបានសម្រេចដាក់ចេញនូវវិធានការចាំបាច់ជាបន្ទាន់មួយចំនួន ក្នុងនោះរួមមានការពង្រឹងបន្ថែមលើការគ្រប់គ្រងធនធានជលផល ដោយរាប់បញ្ចូលទាំងការរឹតបន្តឹងការអនុវត្តវិធានការអភិរក្សសត្វផ្សោត និងការដោះស្រាយភាពមិនប្រក្រតីមួយចំនួនក្នុងមូលដ្ឋាន ការបង្កើនចំនួននៃការល្បាតទាំងនៅពេលថ្ងៃ និងពេលយប់នៅទូទាំងតំបន់នៃទីជម្រកសត្វផ្សោតរស់នៅដើម្បីអភិរក្សចំនួនសត្វផ្សោតដែលនៅសេសសល់កុំឲ្យបាត់បង់ ព្រមទាំងការពារបណ្តាត្រីមេពូជ និងធនធានជលផលសំខាន់ៗដទៃទៀត។

សត្វផ្សោតទន្លេមេគង្គត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់ជលផលរបស់កម្ពុជា។ សត្វផ្សោតត្រូវបានចាត់ថ្នាក់ថាជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជបំផុតនៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ដែលជាចំណាត់ថ្នាក់សកលខ្ពស់បំផុតនៃប្រភេទរងការគំរាមកំហែង។ ជំរឿនសត្វផ្សោតទន្លេមេគង្គឆ្នាំ ២០២០ បានប៉ាន់ប្រមាណថាសត្វផ្សោតនៅមានចំនួនត្រឹមតែ ៨៩ ក្បាលប៉ុណ្ណោះ ដែលកំពុងរស់នៅក្នុងតំបន់ទីជម្រកតាមដងទន្លេមេគង្គប្រវែង ១៨០ គីឡូម៉ែត្រក្នុងប្រទេសកម្ពុជា។

* * *